**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៤០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## សន្តិសុខនាវា និងសន្តិសុខឋបនីយភណ្ឌផែ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

-យោងអនុសញ្ញាអន្តរជាតិស្តីពីសុវត្ថិភាពអាយុជីវិតមនុស្សក្នុងនាវាចរណ៍ឆ្នាំ ១៩៧៤ និងវិសោធនកម្មនានា នៃអនុសញ្ញានេះ

-តាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅគ្រប់គ្រងសន្តិសុខនាវា និងសន្តិសុខបរិវេណកំពង់ផែ នៃព្រះរាជាណាចក្រកម្ពុជា សំដៅបង្កើតកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយរដ្ឋាភិបាលជាប់កិច្ចសន្យា ក្រុមហ៊ុននាវា និងកំពង់ផែ លើវិស័យដឹកជញ្ជូនផ្លូវសមុទ្រ ។

**មាត្រា ២.-**

អនុក្រឹត្យនេះ អនុវត្តចំពោះ :

១-នាវា ដែលធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ មានជាអាទិ :

ក-នាវាអ្នកដំណើរគ្រប់ប្រភេទ

ខ-នាវាទំនិញគ្រប់ប្រភេទ ដែលមានចំណុះសរុបចាប់ពីប្រាំរយ (500 )GT ឡើងទៅ

គ-នាវាខួង ។

២-កំពង់ផែ ដែលបំរើសេវាឱ្យនាវា ដូចមានចែងនៅក្នុងចំណុច ១ នៃមាត្រានេះ ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មិនអនុវត្តចំពោះ :

១-នាវាយោធា

២-នាវារបស់រដ្ឋ ដែលមិនបំរើគោលដៅពាណិជ្ជកម្ម

៣-កំពង់ផែយោធា

**មាត្រា ៤.-**

នាវា ត្រូវមាននាយសន្តិសុខនាវា របាយការណ៍នៃការវាយតម្លៃសន្តិសុខនាវា ផែនការសន្តិសុខនាវា ឬការកែប្រែនៃផែនការនេះ និងឯកសារដទៃទៀត ស្របតាមអនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិក ។

កំពង់ផែ ត្រូវមាននាយសន្តិសុខបរិវេណកំពង់ផែ របាយការណ៍នៃការវាយតម្លៃសន្តិសុខបរិវេណកំពង់ផែ ផែនការសន្តិសុខបរិវេណកំពង់ផែ ឬកែប្រែនៃផែនការនេះ និងឯកសារដទៃទៀត ស្របតាមអនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិក ។

ក្រុមហ៊ុននាវា ត្រូវមាននាយសន្តិសុខក្រុមហ៊ុនសម្រាប់នាវាមួយ ឬច្រើន ឬក្រុមនៃនាវា ។

**មាត្រា ៥.-**

ការវាយតម្លៃសន្តិសុខនាវា និងការរៀបចំផែនការសន្តិសុខនាវា ការពិនិត្យឡើងវិញ ឬការកែប្រែ ព្រមទាំងការអនុវត្តផែនការនេះ ជាបន្ទុកចំណាយរបស់ក្រុមហ៊ុននាវា ។

ការវាយតម្លៃសន្តិសុខឋបនីយភណ្ឌផែ និងការរៀបចំផែនការសន្តិសុខឋបនីយភណ្ឌផែ ការពិនិត្យឡើងវិញ ឬការកែប្រែ ព្រមទាំងការអនុវត្តផែនការនេះ ជាបន្ទុកចំណាយរបស់កំពង់ផែ ។

**មាត្រា ៦.-**

ការគ្រប់គ្រងសន្តិសុខនាវានិងសន្តិសុខឋបនីយភណ្ឌផែ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

ការគ្រប់គ្រងសន្តិសុខនាវាសំរាប់នាវាសញ្ជាតិខ្មែរ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ។

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ត្រូវប្រើប្រាស់នាយកដ្ឋាននាវាជំនួញសមុទ្រ ជាលេខាធិការដ្ឋាន ដើម្បីធ្វើជាសេនាធិការ ។

**មាត្រា ៧.-**

ពាក្យបច្ចេកទេស ដែលប្រើប្រាស់នៅក្នុងអនុក្រឹត្យនេះ រួមមាន :

**ផែនការសន្តិសុខនាវា** (Ship Security Plan ) សំដៅដល់ ផែនការដែលបានកសាងឡើង ដើម្បីធានាអនុវត្តវិធានការនានានៅលើនាវា ក្នុងទិសដៅការពារអាយុជីវិតមនុស្ស ទំនិញនៅលើនាវា និងនាវាទល់នឹងហានិភ័យនៃឧប្បត្តិហេតុសន្តិសុខ ។

**ឋបនីយភណ្ឌផែ** (Port Facility ) សំដៅដល់ ទីតាំងដែលមានប្រតិបត្តិការរវាងនាវា និងផែ និងដែលត្រូវកំណត់ដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។ ឋបនីយភណ្ឌផែ មានជាអាទិ៍ តំបន់ចំណត តំបន់បោះយុថ្កា តំបន់រង់ចាំ ប្រឡាយ និងពាម ព្រមទាំងសំណង់ និងឧបករណ៍សំភារៈនានា ។

**ប្រតិបត្តិការរវាងនាវា និងផែ** (Ship/Port Interface ) សំដៅដល់ សកម្មភាពផ្ទេរផ្ទុករវាងនាវា និងផែ ។

**ប្រតិបត្តិការរវាងនាវា និងនាវា** (Ship-To-Ship Activity) សំដៅដល់ សកម្មភាពផ្ទេរផ្ទុករវាងនាវា និងនាវា ។

**ឧប្បត្តិហេតុសន្តិសុខ** (Security Incident ) សំដៅដល់ សកម្មភាពគួរសង្ស័យណាមួយ ឬហេតុការណ៍ដែលគំរាមកំហែងដល់សន្តិសុខនៃនាវា ឋបនីយភណ្ឌផែ ប្រតិបត្តិការរវាងនាវានិងផែ និងប្រតិបត្តិការរវាងនាវានិង នាវា ។

**ផែនការសន្តិសុខឋបនីយភណ្ឌផែ** ( Port Facility Security Plan ) សំដៅដល់ ផែនការដែលបានកសាង ឡើង ដើម្បីធានាអនុវត្តវិធានការនានា ក្នុងទិសដៅការពារអាយុជីវិតមនុស្ស ទំនិញ នាវាភ័ណ្ឌ នាវា និងឋបនីយភណ្ឌផែ ទល់នឹងហានិភ័យនៃឧប្បត្តិហេតុសន្តិសុខ ។

**នាយសន្តិសុខនាវា** ( Ship Security Officer ) សំដៅដល់ មនុស្សនៅលើនាវា ដែលតែងតាំងដោយក្រុមហ៊ុននាវា ដើម្បីទទួលខុសត្រូវលើការងារសន្តិសុខនាវា រួមទាំងការអនុវត្ត និងរក្សាផែនការសន្តិសុខនាវា ដោយសហការ ជាមួយនាយសន្តិសុខក្រុមហ៊ុន និងនាយសន្តិសុខបរិយាកាសកំពង់ផែ ។

**នាយសន្តិសុខក្រុមហ៊ុន** (Company Security Officer ) សំដៅដល់ មនុស្សដែលតែងតាំងដោយក្រុមហ៊ុននាវា ដើម្បីធានាឱ្យមានការវាយតម្លៃសន្តិសុខនាវា ធានាឱ្យមានការកសាងផែនការសន្តិសុខនាវា និងការសុំអនុម័តលើផែនការនេះ ហើយបន្ទាប់មកធានាឱ្យមានការអនុវត្ត និងរក្សាផែនការនេះ ព្រមទាំងសហការជាមួយនាយសន្តិសុខ នាវានិងនាយសន្តិសុខបរិយាកាសកំពង់ផែ ។

**នាយសន្តិសុខបរិយាកាសកំពង់ផែ** (Port Facility Security Officer ) សំដៅដល់ មនុស្សដែលតែងតាំងដោយស្ថាប័នសមត្ថកិច្ចកំពង់ផែ ដើម្បីទទួលខុសត្រូវចំពោះការកសាង ការអនុវត្ត ការពិនិត្យឡើងវិញ និងការរក្សាផែនការសន្តិសុខបរិយាកាសកំពង់ផែ និងសហការជាមួយនឹងនាយសន្តិសុខនាវា និងនាយសន្តិសុខក្រុមហ៊ុន ។

**ស្ថាប័នសមត្ថកិច្ចកំពង់ផែ** ( Competent Institution of Port ) សំដៅដល់ នីតិបុគ្គលនៃកំពង់ផែ ដែលមានជាអាទិ៍ ប្រធានកំពង់ផែ អគ្គនាយកកំពង់ផែ ឬនាយកកំពង់ផែ ។

**អង្គការសន្តិសុខទទួលស្គាល់** (Recognized Security Organization) សំដៅដល់ អង្គការសន្តិសុខដែលបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ។

**សន្តិសុខកម្រិតទី១** (Security Level 1 ) សំដៅដល់ កម្រិតសន្តិសុខដែលក្នុងនោះគេត្រូវប្រតិបត្តិនៅគ្រប់ពេលវេលានូវវិធានការការពារសន្តិសុខកម្រិតអប្បបរមាសមស្រប ។

**សន្តិសុខកម្រិតទី២** (Security Level 2 ) សំដៅដល់ កម្រិតសន្តិសុខដែលក្នុងនោះគេត្រូវប្រតិបត្តិនៅពេលវេលាមួយជាក់លាក់ នូវវិធានការការពារសន្តិសុខបន្ថែមសមស្រប ដោយហានិភ័យធ្ងន់ធ្ងរនៃឧប្បត្តិហេតុសន្តិសុខនឹងកើតមានឡើង ។

**សន្តិសុខកម្រិតទី៣** (Security Level 3 ) សំដៅដល់ កម្រិតសន្តិសុខដែលក្នុងនោះគេត្រូវប្រតិបត្តិនូវវិធានការការពារសន្តិសុខលំអិតជាក់លាក់ នៅក្នុងពេលវេលាខ្លីមួយ ដែលឧប្បត្តិហេតុសន្តិសុខ នឹងកើតមានឡើង បើទោះបីជាគេ ពុំអាចកំណត់បាននូវគោលដៅច្បាស់លាស់ក៏ដោយ ។

**នាវា** (Ship ) សំដៅដល់ :

១-នាវាសញ្ជាតិខ្មែរ

២-នាវាបរទេស ដែលចូលមកក្នុងដែនទឹកនៃព្រះរាជាណាចក្រកម្ពុជា ឬនៅតាមកំពង់ផែនៃព្រះរាជាណា ចក្រកម្ពុជា ។

**កំពង់ផែ** (Port ) សំដៅដល់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តក្រុងភ្នំពេញ ឬកំពង់ផែអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដែលកំណត់ដោយរាជរដ្ឋាភិបាល ។

**ច្បាប់អន្តរជាតិ** (International Law ) សំដៅដល់ ច្បាប់អន្តរជាតិទាំងឡាយណា ដែលពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូនផ្លូវសមុទ្រ ហើយដែលមានការចូលរួមពីព្រះរាជាណាចក្រកម្ពុជា ។

**ច្បាប់ជាតិ** សំដៅដល់ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**រដ្ឋាភិបាលជាប់កិច្ចសន្យា** (Contracting Governments ) សំដៅដល់ រដ្ឋាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច នៃរដ្ឋជាសមាជិកអនុសញ្ញាអន្តរជាតិ ស្តីពីសុវត្ថិភាពអាយុជីវិតក្នុងនាវាចរណ៍ឆ្នាំ ១៩៧៤ និងវិសោធនកម្មនៃអនុសញ្ញានេះ ។

**គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា** សំដៅដល់ គណៈកម្មាធិការអន្តរក្រសួង ដែលតែងតាំងដោយរាជរដ្ឋាភិបាល តាមសេចក្តីសំរេចលេខ ៣២ ស.សរ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៣ សម្រាប់គ្រប់គ្រងនាវាសញ្ជាតិខ្មែរ ។

**សមត្ថកិច្ចត្រួតពិនិត្យនាវា** ( Port State Control Officer ) សំដៅដល់ មន្ត្រីរាជការជំនាញ ដែលបានទទួលការអនុញ្ញាតពីក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីធ្វើការត្រួតពិនិត្យ និងអង្កេតនាវា ដែលចូលមកតាមកំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា ដោយគោរពតាមបទប្បញ្ញត្តិនៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។

GT (Gross Tonnage ) សំដៅដល់ ខ្នាត " ចំណុះផ្ទុកសរុបរបស់នាវា " ដែលអាចគណនាតាមរូបមន្ត $GT=K_1.V$ ក្នុងនោះ :

- $K_1=0.2+0.02 \log_{10} V$ ជាមេគុណ
- V ជាមាឌលំហរក្នុងសរុបរបស់នាវា គិតជាម៉ែត្រគ្រីគុណ ។

## ជំពូកទី ២
## ការគ្រប់គ្រង

**មាត្រា ៨.-**

ក្រសួងសាធារណការនិងដឹកជញ្ជូន មានភារកិច្ច និងភារកិច្ចដូចតទៅ :

**ក.ភារកិច្ច :**

១-រៀបចំសេចក្តីព្រាងច្បាប់ ឬវិធាននានា ដើម្បីអនុវត្តឱ្យបានពេញលេញ និងមានប្រសិទ្ធភាពនូវច្បាប់អន្តរជាតិ ។

២-រៀបចំក៏រិតសន្តិសុខបរិយាកាសកំពង់ផែ ។

៣-ពិនិត្យ និងយល់ព្រមលើការវាយតម្លៃសន្តិសុខបរិយាកាសកំពង់ផែ និងការកែប្រែនៃការវាយតម្លៃនេះ ។

៤-ពិនិត្យ និងយល់ព្រមលើផែនការសន្តិសុខថបនីយភណ្ឌផែ និងការកែប្រែនៃផែនការនេះ ។

៥-ពិនិត្យ និងផ្តល់លិខិតបញ្ជាក់ថបនីយភណ្ឌផែ ។

៦-រៀបចំប្រតិវេទន៍សន្តិសុខ ។

៧-កំណត់ថបនីយភណ្ឌផែណា ដែលត្រូវមាននាយសន្តិសុខថបនីយភណ្ឌផែ ។

៨-ជ្រើសរើស និងតែងតាំងអង្គការសន្តិសុខទទួលស្គាល់ សម្រាប់ថបនីយភណ្ឌផែ ។

៩-អនុវត្តច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។

១០-ជូនដំណឹងអំពីវិធាននានាទៅអង្គការសមុទ្រអន្តរជាតិ នាវា ក្រុមហ៊ុននាវា និងកំពង់ផែ ។

**ខ-ភារកិច្ច :**

១-ធានាឱ្យមានការបណ្តុះបណ្តាល ការហ្វឹកហាត់ និងលំហាត់អនុវត្តលើកិច្ចការសន្តិសុខថបនីយភណ្ឌផែ ។

២-ត្រួតពិនិត្យសាកល្បងលើផែនការសន្តិសុខថបនីយភណ្ឌផែ ។

៣-សហការសុំអន្តរាគមន៍ពីក្រសួងពាក់ព័ន្ធក្នុងករណីចាំបាច់ ។

**មាត្រា ៩.-**

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា មានកាតព្វកិច្ចនិងភារកិច្ចដូចតទៅ:

**ក-កាតព្វកិច្ច :**

១-ចាត់ចែងរៀបចំកំរិតសន្តិសុខនាវា ។

២-ជ្រើសរើស និងតែងតាំងអង្គការសន្តិសុខទទួលស្គាល់សម្រាប់នាវាសញ្ជាតិខ្មែរ ។

**ខ-ភារកិច្ច :**

១-ជំរុញឱ្យបានសម្រេចនូវការវាយតម្លៃសន្តិសុខនាវា ការកសាងផែនការសន្តិសុខនាវា ការពិនិត្យឡើងវិញ ឬការកែប្រែនៃផែនការនេះ ។

២-ពិនិត្យ និងយល់ព្រមលើផែនការសន្តិសុខនាវា ឬការកែប្រែនៃផែនការនេះ ។

៣-ពិនិត្យ និងផ្តល់វិញ្ញាបនប័ត្រសន្តិសុខនាវា ឬឯកសារចាំបាច់សម្រាប់នាវា ។

៤-ត្រួតពិនិត្យសាកល្បងលើផែនការសន្តិសុខនាវា ។

៥-ធានាឱ្យមានការបណ្តុះបណ្តាល ការហ្វឹកហាត់ និងលំហាត់អនុវត្តលើកិច្ចការសន្តិសុខនាវា ។

៦-សហការ និងសុំអន្តរាគមន៍ពីក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងករណីចាំបាច់ ។

**មាត្រា ១០.-**

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវជ្រើសរើស និងតែងតាំងប្រតិបត្តិករកំពង់ផែ អង្គភាពជំនាញ ឬអង្គការសន្តិសុខទទួលស្គាល់ណាមួយ ជាអង្គការសន្តិសុខសម្រាប់បរិយាកាសកំពង់ផែ បើប្រតិបត្តិករកំពង់ផែ អង្គភាពជំនាញ ឬអង្គការសន្តិសុខនោះ មានសមត្ថភាពវិជ្ជាជីវៈសមស្រប ។

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ត្រូវជ្រើសរើសនិងតែងតាំងអង្គការសន្តិសុខទទួលស្គាល់ណាមួយ ជាអង្គការសន្តិសុខសម្រាប់នាវាសញ្ជាតិខ្មែរ បើអង្គការសន្តិសុខនោះ មានសមត្ថភាពវិជ្ជាជីវៈសមស្រប ។

**មាត្រា ១១.-**

អង្គការសន្តិសុខទទួលស្គាល់ អាចទទួលឱ្យបំពេញភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

១-ធ្វើការវាយតម្លៃសន្តិសុខនាវា កសាងផែនការសន្តិសុខនាវា ឬធ្វើការកែប្រែនៃផែនការនេះ ។

២-ធ្វើការវាយតម្លៃសន្តិសុខបរិយាកាសកំពង់ផែ កសាងផែនការសន្តិសុខបរិយាកាសកំពង់ផែ ឬធ្វើការកែប្រែនៃផែនការនេះ ។

៣-ពិនិត្យ និងយល់ព្រមលើផែនការសន្តិសុខនាវា ។

៤-ផ្តល់យោបល់ដល់ក្រុមហ៊ុននាវា ឬបរិយាកាសកំពង់ផែលើការងារសន្តិសុខ ។

៥-ត្រួតពិនិត្យបច្ចេកទេស និងផ្តល់វិញ្ញាបនប័ត្រសន្តិសុខឱ្យនាវា ។

**មាត្រា ១២.-**

អង្គការសន្តិសុខទទួលស្គាល់ ដែលបានធ្វើការវាយតម្លៃសន្តិសុខនាវា ឬកសាងផែនការសន្តិសុខនាវាមិនត្រូវបានអនុញ្ញាតឱ្យពិនិត្យ និងយល់ព្រមលើការវាយតម្លៃសន្តិសុខនាវា ឬលើ ផែនការសន្តិសុខនាវានោះបានឡើយ ។

**មាត្រា ១៣.-**

នាយសន្តិសុខនាវា ត្រូវមានការទទួលខុសត្រូវដូចខាងក្រោម៖

១-ត្រួតពិនិត្យសន្តិសុខនាវាជាទៀងទាត់ ។

២-រក្សា និងត្រួតពិនិត្យការអនុវត្តផែនការសន្តិសុខនាវា និងការកែប្រែនៃផែនការនេះ ។

៣-សហការជាមួយបុគ្គលិកនាវា និងនាយសន្តិសុខបរិយាកាសកំពង់ផែ លើរាល់ការងារសន្តិសុខនៃការលើកដាក់ទំនិញនិងនាវាកណ្តាល ។

៤-សហការជាមួយនាយសន្តិសុខក្រុមហ៊ុន និងនាយសន្តិសុខបរិយាកាសកំពង់ផែ ក្នុងការអនុវត្តផែនការសន្តិសុខនាវា ។

៥-លើកសំណើកែលំអផែនការសន្តិសុខនាវា ។

៦-ធ្វើរបាយការណ៍ជូននាយសន្តិសុខក្រុមហ៊ុននូវរាល់ចំណុចខ្វះខាត និងការមិនសមស្របតាមផែនការដែលបានរកឃើញនៅពេលៈ

ក-សវនកម្មផ្ទៃក្នុង

ខ-ការពិនិត្យឡើងវិញតាមកាលកំណត់

គ-ការត្រួតពិនិត្យសន្តិសុខ

ឃ-ការផ្ទៀងផ្ទាត់ការអនុវត្តផែនការ ។

៧-បំពេញបន្ថែមនូវចំណុចខ្វះខាត និងការមិនសមស្របតាមផែនការ ដែលបានរកឃើញ ។

៨-លើកកំពស់ការយល់ដឹង និងការប្រុងប្រយ័ត្នអំពីសន្តិសុខនៅលើនាវា ធានាឱ្យមានការបណ្តុះបណ្តាល និងហ្វឹកហាត់ដល់បុគ្គលិកនាវា ។

៩-រាយការណ៍នូវរាល់ឧប្បត្តិហេតុសន្តិសុខ ។

១០-ធានាឱ្យមានដំណើរការល្អក្នុងការប្រើប្រាស់ ការសាកល្បង ការវាស់ស្ទង់ និងការរក្សាឧបករណ៍សន្តិសុខនៅលើនាវា ។

១១-ជួយនាយសន្តិសុខបរិវេណផែ ក្នុងការបញ្ជាក់អំពីអត្តសញ្ញាណនៃជន ដែលចុះមកពីនាវាបើមានការស្នើសុំ ។

**មាត្រា ១៩.-**

នាយសន្តិសុខក្រុមហ៊ុន ត្រូវមានការទទួលខុសត្រូវដូចខាងក្រោមៈ

១-ផ្តល់យោបល់អំពីកំរិតនៃការគំរាមកំហែង ដែលអាចនឹងកើតមានចំពោះនាវា ដោយផ្អែកលើរបាយការណ៍នៃការវាយតម្លៃសន្តិសុខ និងព័ត៌មាននានា ។

២-ធានាឱ្យមានការប្រព្រឹត្តិទៅនៃការវាយតម្លៃសន្តិសុខនាវា ។

៣-ធានាឱ្យមានការកសាង ការស្នើសុំការយល់ព្រម និងបន្ទាប់មកធានាឱ្យមានការអនុវត្ត និងថែរក្សាផែនការសន្តិសុខនាវា ។

៤-ធានាឱ្យមានការកែលំអផែនការសន្តិសុខនាវា ដើម្បីកែចំណុចខ្វះខាត និងបំពេញនូវលក្ខខ័ណ្ឌសន្តិសុខរបស់នាវានីមួយៗ ។

៥-រៀបចំសវនកម្មផ្ទៃក្នុង និងពិនិត្យឡើងវិញនូវរាល់សកម្មភាពសន្តិសុខនាវា ។

៦-រៀបចំឱ្យមានដំណើរការផ្ទៀងផ្ទាត់សន្តិសុខនាវានៅគ្រាដំបូង និងគ្រាបន្តបន្ទាប់ ដែលធ្វើឡើងដោយគណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ។

៧-ធានាដោះស្រាយ ឱ្យទាន់ពេលវេលានូវរាល់ចំណុចខ្វះខាត និងការមិនគោរពតាមផែនការសន្តិសុខនាវា ដែលបានពិនិត្យឃើញនៅពេលៈ

ក.សវនកម្មផ្ទៃក្នុង

ខ.ការពិនិត្យឡើងវិញតាមកាលកំណត់

គ.ការត្រួតពិនិត្យសន្តិសុខ

ឃ.ការផ្ទៀងផ្ទាត់ការអនុវត្តផែនការសន្តិសុខនាវា ។

៨-លើកកំពស់ការយល់ដឹង និងការប្រុងប្រយ័ត្នអំពីសន្តិសុខនាវា ។

៩-ធានាឱ្យមានការបណ្តុះបណ្តាល និងការហ្វឹកហ្វឺនគ្រប់គ្រាន់ដល់បុគ្គលិកដែលទទួលខុសត្រូវលើការងារសន្តិសុខនាវា ។

១០-ធានាទំនាក់ទំនងព័ត៌មាន និងសហប្រតិបត្តិការរវាងនាយសន្តិសុខនាវា និងនាយសន្តិសុខបរិយកណ្ឌផែឱ្យមានប្រសិទ្ធភាព ។

១១-ធានាឱ្យមានភាពស៊ីសង្វាក់គ្នារវាងលក្ខខ័ណ្ឌសន្តិសុខ និងលក្ខខ័ណ្ឌសុវត្ថិភាព ។

១២-ធានាឱ្យផែនការសន្តិសុខនាវាសម្រាប់នាវានីមួយៗ មានភាពសមស្របទៅនឹងព័ត៌មាននាវានោះ ក្នុងករណីដែលផែនការនោះ ជាផែនការនៃនាវា ឬក្រុមនាវាដែលមានលក្ខណៈបច្ចេកទេសប្រហាក់ប្រហែលគ្នា។

១៣-ធានាឱ្យមានការអនុវត្ត និងរក្សានូវការចាត់ចែងដោយឡែកណាមួយ ឬការចាត់ចែងប្រហាក់ប្រហែលគ្នាសម្រាប់នាវាមួយ ឬក្រុមនាវាណាមួយ ។

**មាត្រា ១៥.-**

នាយសន្តិសុខបរិយកណ្ឌផែ ត្រូវមានការទទួលខុសត្រូវដូចខាងក្រោមៈ

១-ធ្វើការអង្កេតសន្តិសុខជាទូទៅនៅកំពង់ផែ ដោយផ្អែកលើការវាយតម្លៃសន្តិសុខបរិយកណ្ឌ ផែ ។

២-ធានាកសាង និងរក្សាផែនការសន្តិសុខបរិយកណ្ឌផែ ។

៣-អនុវត្តផែនការសន្តិសុខបរិយកណ្ឌផែ ។

៤-ត្រួតពិនិត្យសន្តិសុខបរិយកណ្ឌផែជាទៀងទាត់ ដើម្បីធានានិរន្តរភាពនៃវិធានការសន្តិសុខ ។

៥-ផ្តល់អនុសាសន៍ និងបញ្ចូលនូវរាល់ការកែប្រែទាំងឡាយទៅក្នុងផែនការសន្តិសុខបរិយកណ្ឌផែ ដើម្បីកែនូវចំណុចខ្វះខាត និងកែលំអផែនការនេះ ក្នុងករណីចាំបាច់ ។

៦-លើកកំពស់ការយល់ដឹង និងការប្រុងប្រយ័ត្នអំពីសន្តិសុខដល់បុគ្គលិកកំពង់ផែ។

៧-ធានាផ្តល់ការបណ្តុះបណ្តាល និងការហ្វឹកហ្វឺនគ្រប់គ្រាន់ដល់បុគ្គលិក ដែលទទួលខុសត្រូវផ្នែកសន្តិសុខបរិយកណ្ឌផែ ។

៨-រាយការណ៍ទៅសមត្ថកិច្ចពាក់ព័ន្ធ និងរក្សានូវកំណត់ហេតុអំពីឧប្បត្តិហេតុនានា ដែលគំរាមកំហែង ដល់សន្តិសុខបរិវេណកំពង់ផែ ។

៩-អនុវត្តផែនការសន្តិសុខបរិវេណកំពង់ផែ ដោយសហការជាមួយនាយសន្តិសុខក្រុមហ៊ុន នាយសន្តិសុខនាវា ឬសេវាកម្មសន្តិសុខនានា ។

១០-ធានាឱ្យមានបទដ្ឋានសមស្របសម្រាប់បុគ្គលិក ដែលទទួលមុខនាទីផ្នែកសន្តិសុខបរិវេណកំពង់ផែ ។

១១-ធានាឱ្យមានដំណើរការល្អ ក្នុងការប្រើប្រាស់ ការសាកល្បង ការវាស់ស្ទង់ និងការរក្សាឧបករណ៍សន្តិសុខនៅកំពង់ផែ ។

១២-ជួយនាយសន្តិសុខនាវា ក្នុងការបញ្ជាក់អំពីអត្តសញ្ញាណនៃជនដែលឡើងលើនាវា បើមានការស្នើសុំ

## មាត្រា ១៦.-

ក្រុមហ៊ុននាវា ត្រូវមានការទទួលខុសត្រូវដូចតទៅ:

១-ផ្តល់សិទ្ធិ និងការទទួលខុសត្រូវពេញលេញ ដល់មេបញ្ជាការនាវា ក្នុងការសម្រេចចិត្តនានាពាក់ព័ន្ធ នឹងសុវត្ថិភាព និងសន្តិសុខនាវា ។

២-ផ្តល់សិទ្ធិ និងការទទួលខុសត្រូវពេញលេញ ដល់នាយសន្តិសុខក្រុមហ៊ុន មេបញ្ជាការនាវា និងនាយសន្តិសុខនាវាស្របតាមច្បាប់អន្តរជាតិ ។

## មាត្រា ១៧.-

ក្រុមហ៊ុននាវា ត្រូវជ្រើសរើសយកអង្គការសន្តិសុខទទួលស្គាល់ណាមួយ ឬច្រើន ដូចមានចែងនៅក្នុង មាត្រា ១០ នៃអនុក្រឹត្យនេះ ដើម្បីធ្វើការវាយតម្លៃសន្តិសុខនាវា ឬកសាងផែនការសន្តិសុខនាវា ឬការកែប្រែនៃផែនការនេះ ។

ស្ថាប័នសមត្ថកិច្ចកំពង់ផែ អាចជ្រើសរើសអង្គការសន្តិសុខទទួលស្គាល់ណាមួយ ដូចមានចែងនៅក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ ដើម្បីធ្វើការវាយតម្លៃសន្តិសុខបរិវេណកំពង់ផែ ឬកសាងផែនការសន្តិសុខបរិវេណកំពង់ផែ ឬការកែប្រែនៃផែនការនេះ ។

## មាត្រា ១៨.-

ក្រុមហ៊ុននាវា ត្រូវជ្រើសរើស និងតែងតាំងនាយសន្តិសុខនាវា និងនាយសន្តិសុខក្រុមហ៊ុន បើនាយសន្តិសុខទាំងនោះ មានសមត្ថភាពវិជ្ជាជីវៈសមស្រប ។

ក្រុមហ៊ុននាវា ឬមេបញ្ជាការនាវា ឬនាយសន្តិសុខនាវា ឬនាយសន្តិសុខក្រុមហ៊ុន ត្រូវជ្រើសរើសបុគ្គលិកនាវា ដែលមានភារកិច្ចសន្តិសុខតាមផ្នែកសន្តិសុខ បើបុគ្គលិកនាវានោះ មានសមត្ថភាពវិជ្ជាជីវៈសមស្រប ។

**មាត្រា ១៩.-**

ក្រុមហ៊ុននាវា ត្រូវធានាផ្តល់ការហ្វឹកហាត់សមស្របដល់បុគ្គលិកនាវា ដែលមានភារកិច្ចសន្តិសុខតាមផ្នែកសន្តិសុខនៅគ្រប់កំរិតសន្តិសុខ ដែលមានកំណត់នៅក្នុងផែនការសន្តិសុខនាវា នៅរៀងរាល់បី (៣) ខែម្តង ឬបើក្នុងករណីមានការផ្លាស់ប្តូរបុគ្គលិកនាវារហូតដល់ម្ភៃប្រាំភាគរយ (២៥%) នោះការហ្វឹកហាត់ ត្រូវធ្វើឡើងក្នុងរយៈពេលមួយ(១) សប្តាហ៍ បន្ទាប់ពីមានការផ្លាស់ប្តូរនេះ ។

ក្រុមហ៊ុននាវា ត្រូវធានាឱ្យមានការហាត់អនុវត្តសមស្របនៅរៀងរាល់ដប់ប្រាំបី (១៨) ខែម្តង ក្នុងនោះត្រូវមានការចូលរួមពីនាយសន្តិសុខក្រុមហ៊ុន នាយសន្តិសុខថបនីយភណ្ឌផែ សមត្ថកិច្ចពាក់ព័ន្ធ ឬនាយសន្តិសុខនាវា ។

**មាត្រា ២០.-**

ស្ថាប័នសមត្ថកិច្ចកំពង់ផែ ត្រូវជ្រើសរើស និងតែងតាំងនាយសន្តិសុខថបនីយភណ្ឌផែ បើនាយសន្តិសុខនោះមានសមត្ថភាពវិជ្ជាជីវៈសមស្រប ។

តាមសំណើរបស់នាយសន្តិសុខថបនីយភណ្ឌផែ ស្ថាប័នសមត្ថកិច្ចកំពង់ផែ ត្រូវជ្រើសរើសបុគ្គលិកកំពង់ផែដែលមានភារកិច្ចសន្តិសុខតាមផ្នែកសន្តិសុខ បើបុគ្គលិកកំពង់ផែនោះ មានសមត្ថភាពវិជ្ជាជីវៈសមស្រប ។

**មាត្រា ២១.-**

ស្ថាប័នសមត្ថកិច្ចកំពង់ផែ ត្រូវធានាផ្តល់ការហ្វឹកហាត់សមស្របដល់បុគ្គលិកកំពង់ផែ ដែលមានភារកិច្ចសន្តិសុខតាមផ្នែកសន្តិសុខនៅគ្រប់កំរិតសន្តិសុខ ដែលមានកំណត់នៅក្នុងផែនការសន្តិសុខថបនីយភណ្ឌផែ នៅរៀងរាល់បី (៣) ខែម្តង លើកលែងតែក្នុងករណីចាំបាច់ ។

ស្ថាប័នសមត្ថកិច្ចកំពង់ផែ ត្រូវធានាឱ្យមានការហាត់អនុវត្តសមស្របនៅរៀងរាល់ដប់ប្រាំបី (១៨) ខែម្តង ក្នុងនោះត្រូវមានការចូលរួមពីនាយសន្តិសុខថបនីយភណ្ឌផែ សមត្ថកិច្ចពាក់ព័ន្ធ និងពីនាយសន្តិសុខក្រុមហ៊ុននាវា ឬនាយសន្តិសុខនាវា បើមានការស្នើសុំ ។

**មាត្រា ២២.-**

សមត្ថភាពវិជ្ជាជីវៈសមស្របដូចមានចែងនៅក្នុងមាត្រា ១០ មាត្រា ១៨ និងមាត្រា ២០ ព្រមទាំងការហ្វឹកហាត់ និងការហាត់អនុវត្តសមស្របដូចមានចែងនៅក្នុងមាត្រា ១៩ និងមាត្រា ២១ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ស្របតាមស្មារតីនៃអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធ ។

**មាត្រា ២៣.-**

ផែនការសន្តិសុខថបនីយភណ្ឌផែ និងការកែប្រែនៃផែនការនេះ និងប្រតិវេទន៍សន្តិសុខនាវា ត្រូវរៀបចំឡើងជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលមានតំលៃស្មើគ្នា ។

**មាត្រា ២៤.-**

ផែនការសន្តិសុខបរិយាយកណ្តផែ ការកែប្រែនៃផែនការនេះ រួមទាំងរបាយការណ៍នៃការវាយតម្លៃសន្តិសុខបរិយាយកណ្តផែ ត្រូវបានរក្សាទុកនៅកំពង់ផែ និងក្រសួងសាធារណការនិងដឹកជញ្ជូន ។

ផែនការសន្តិសុខនាវា ការកែប្រែនៃផែនការនេះ រួមទាំងរបាយការណ៍នៃការវាយតម្លៃសន្តិសុខនាវា ត្រូវបានរក្សាទុកនៅលើនាវា និងក្រុមហ៊ុននាវា ។

ប្រតិវេទន៍សន្តិសុខ ត្រូវបានរក្សាទុកនៅលើនាវា និងបរិយាយកណ្តផែ ។

ការរក្សាទុកនៃផែនការសន្តិសុខបរិយាយកណ្តផែ ផែនការសន្តិសុខនាវា និងការកែប្រែផែនការទាំងនេះ ត្រូវធ្វើឡើងសំរាប់រយៈពេលប្រាំ (៥) ឆ្នាំយ៉ាងតិច ។

**មាត្រា ២៥.-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវចេញប្រកាស និងសារាចរណែនាំលំអិត ដើម្បីអនុវត្តអនុក្រឹត្យនេះ ។

ក្នុងករណីចាំបាច់ ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីចេញប្រកាសអន្តរក្រសួង ។

## ជំពូកទី ៣
## សន្តិសុខនាវា

**មាត្រា ២៦.-**

សន្តិសុខនាវា មានបីកំរិត ហើយកំរិតនីមួយៗ ត្រូវមាននៅក្នុងផែនការសន្តិសុខនាវា ។

សន្តិសុខកំរិតទី១ ត្រូវបានរៀបចំឡើងដើម្បីកំណត់អត្តសញ្ញាណ និងចាត់វិធានការទប់ស្កាត់ឧប្បត្តិហេតុសន្តិសុខ ។វិធានការនេះរួមមាន:

១-ធានាការអនុវត្តភារកិច្ចសន្តិសុខនាវា ។

២-ត្រួតពិនិត្យការចូលទៅកាន់នាវា ។

៣-ត្រួតពិនិត្យអ្នកឡើងលើនាវា និងសំភារៈផ្ទាល់ខ្លួន ។

៤-ឃ្លាំមើលតំបន់ហាមឃាត់ ដើម្បីធានាថា មានតែជនមានការអនុញ្ញាតប៉ុណ្ណោះ ទើបអាចចូលបាន ។

៥-ឃ្លាំមើលគ្រប់ជាន់នៃនាវា និងតំបន់ជុំវិញនាវា ។

៦-ត្រួតពិនិត្យការលើកដាក់ ការថែរក្សា និងការផ្ទេរផ្ទុកទំនិញ និងនាវាភ័ណ្ឌ ។

៧-ធានាឱ្យមានភាពងាយ ស្រួលក្នុងទំនាក់ទំនងសន្តិសុខ ។

សន្តិសុខកំរិតទី២ សំដៅពង្រឹងបន្ថែមលើវិធានការសន្តិសុខកំរិតទី១ ។

សន្តិសុខកំរិតទី៣ សំដៅពង្រឹងបន្ថែមវិធានការការពារជាក់លាក់ ដើម្បីទប់ស្កាត់ឧប្បត្តិហេតុសន្តិសុខឱ្យមានប្រសិទ្ធភាព ។

**មាត្រា ២៧.-**

នាវាសញ្ជាតិខ្មែរ ត្រូវមានវិធានការទាំងបីកំរិត ដូចមានចែងនៅក្នុងអនុក្រឹត្យនេះ និងវិធានពាក់ព័ន្ធ ។

នាវាសញ្ជាតិខ្មែរ មិនត្រូវមានកំរិតសន្តិសុខនាវាទាបជាងកំរិតសន្តិសុខឋបនីយភណ្ឌផែ ដែលនាវានោះចូលដើម្បីផ្ទេរផ្ទុកទំនិញ អ្នកដំណើរ អ្នកទេសចរណ៍ ឬស៊ុំចតបានឡើយ ។

ក្នុងករណី នាវាសញ្ជាតិខ្មែរ មានកំរិតសន្តិសុខនាវាខ្ពស់ជាងកំរិតសន្តិសុខឋបនីយភណ្ឌផែ នាវានោះ ត្រូវមានការឯកភាពគ្នារវាងមេបញ្ជាការនាវា ឬនាយសន្តិសុខនាវា និងនាយសន្តិសុខឋបនីយភណ្ឌផែនៅលើប្រតិវេទន៍ សន្តិសុខ ។

**មាត្រា ២៨.-**

នាវាបរទេស ដែលចូលមកព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់អន្តរជាតិ និងច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

នាវាបរទេស ដែលចូលមកកំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានកំរិតសន្តិសុខស្មើនឹង ឬខ្ពស់ជាងកំរិតសន្តិសុខឋបនីយភណ្ឌផែ ។

ក្នុងករណីនាវាបរទេស មានកំរិតសន្តិសុខខ្ពស់ជាងកំរិតសន្តិសុខឋបនីយភណ្ឌផែ នាវានោះត្រូវមានការឯកភាពគ្នារវាងមេបញ្ជាការនាវា ឬនាយសន្តិសុខនាវា និងនាយសន្តិសុខឋបនីយភណ្ឌផែនៅលើប្រតិវេទន៍សន្តិសុខ ។

**មាត្រា ២៩.-**

ការវាយតម្លៃសន្តិសុខនាវា រួមមានទាំងការអង្កេតសន្តិសុខនៅនឹងកន្លែង និងកត្តាសំខាន់ៗដែលនឹងត្រូវបញ្ចូលទៅក្នុងរបាយការណ៍ ដូចខាងក្រោម៖

១-កំណត់អត្តសញ្ញាណនៃវិធានការ នីតិវិធី និងប្រតិបត្តិការសន្តិសុខ ដែលមានស្រាប់ ។

២-កំណត់អត្តសញ្ញាណ និងការវាយតម្លៃនៃប្រតិបត្តិការគន្លឹះនៅលើនាវា ដែលចាំបាច់ត្រូវការពារ ។

៣-កំណត់អត្តសញ្ញាណនៃការគំរាមកំហែង ដែលអាចនឹងកើតមានចំពោះប្រតិបត្តិការនៅលើនាវា ។

៤-កំណត់អត្តសញ្ញាណនៃចំណុចខ្សោយទាំងឡាយ រួមទាំងកត្តាមនុស្សក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ គោលនយោបាយ និងនីតិវិធី ។

**មាត្រា ៣០.-**

ផែនការសន្តិសុខនាវា ត្រូវបានកសាងឡើងដោយផ្អែកលើរបាយការណ៍នៃការវាយតម្លៃសន្តិសុខនាវា និងការគោរពទៅតាមអនុក្រឹត្យនេះ និងវិធានពាក់ព័ន្ធនានា ។

**មាត្រា ៣១.-**

រាល់ការផ្លាស់ប្តូរផែនការសន្តិសុខនាវា ឬរាល់ការផ្លាស់ប្តូរឧបករណ៍សន្តិសុខ ឬរាល់ការកែប្រែចំណុចណាមួយនៃផែនការសន្តិសុខនាវា ត្រូវមានការយល់ព្រមពីគណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ។

**មាត្រា ៣២.-**

ផែនការសន្តិសុខនាវា និងការកែប្រែនៃផែនការនេះ ត្រូវមានសវនកម្មផ្ទៃក្នុងដើម្បីត្រួតពិនិត្យសកម្មភាពសន្តិសុខ ។

**មាត្រា ៣៣.-**

សវនករផ្ទៃក្នុង ត្រូវមានលក្ខណៈឯករាជ្យពីសកម្មភាពសន្តិសុខ ដែលខ្លួនកំពុងធ្វើសវនកម្ម លើកលែងតែសវនករនោះ ពុំមានសមត្ថភាពគ្រប់គ្រាន់ធ្វើសវនកម្មបាន ដោយអាស្រ័យនឹងទំហំនាវា ឬលក្ខណៈរបស់ក្រុមហ៊ុននាវា ។

**មាត្រា ៣៤.-**

ត្រូវពិនិត្យឡើងវិញ និងកែប្រែផែនការសន្តិសុខនាវា តាមការស្នើសុំរបស់នាយសន្តិសុខនាវា ឬនាយសន្តិសុខក្រុមហ៊ុននៅពេលមានការផ្លាស់ប្តូរឧបករណ៍ និងប្រព័ន្ធសន្តិសុខនាវា ។

## ជំពូកទី ៤
## សន្តិសុខបំបនីយភណ្ឌផែ

**មាត្រា ៣៥.-**

សន្តិសុខបំបនីយភណ្ឌផែ មានបីកំរិត ហើយកំរិតនីមួយៗ ត្រូវមានកំណត់នៅក្នុងផែនការសន្តិសុខបំបនីយភណ្ឌផែ ។

សន្តិសុខកំរិតទី១ ត្រូវបានកសាងឡើងដើម្បីធ្វើអត្តសញ្ញាណ និងចាត់វិធានការទប់ស្កាត់ឧប្បត្តិហេតុសន្តិសុខ ។

វិធានការនេះរួមមានៈ

១-ធានាការអនុវត្តភារកិច្ចសន្តិសុខបំបនីយភណ្ឌផែ ។

២-ត្រួតពិនិត្យការចូលទៅកាន់បំបនីយភណ្ឌផែ

៣-ឃ្លាំមើលកំពង់ផែ រួមទាំងតំបន់បោះយុថ្កា ចំណតនាវា និងតំបន់ជុំវិញកំពង់ផែ ។

៤-ឃ្លាំមើលតំបន់ហាមឃាត់ ដែលធានាថា មានតែជនមានការអនុញ្ញាតប៉ុណ្ណោះ ទើបអាចចូលបាន ។

៥-ត្រួតពិនិត្យការងារសន្តិសុខក្នុងការលើកដាក់ទំនិញ និងនាវាភណ្ឌ ។

៦-ធានាឱ្យមានភាពងាយស្រួលក្នុងទំនាក់ទំនងសន្តិសុខ ។

សន្តិសុខកំរិតទី២ សំដៅពង្រឹងបន្ថែមលើវិធានការសន្តិសុខកំរិតទី១ ។

សន្តិសុខកំរិតទី៣ សំដៅពង្រឹងបន្ថែមវិធានការការពារជាក់លាក់ ដើម្បីទប់ស្កាត់ឧប្បត្តិហេតុសន្តិសុខឱ្យមានប្រសិទ្ធភាព ។

**មាត្រា ៣៦.-**

កំពង់ផែនីមួយៗ ត្រូវមានវិធានការសន្តិសុខទាំងបីកំរិត ។

នាយសន្តិសុខបរិវេណកំពង់ផែ អាចអនុវត្តសន្តិសុខកំរិតទី២ ឬសន្តិសុខកំរិតទី៣ បើជាការចាំបាច់ក្នុងការការពារនឹងឧប្បត្តិហេតុសន្តិសុខណាមួយ ឬមានការគំរាមកំហែងណាមួយ ។

នាយសន្តិសុខបរិវេណកំពង់ផែ អាចអនុវត្តសន្តិសុខកំរិតទី២ ឬសន្តិសុខកំរិតទី៣ បើមានការស្នើសុំពីនាវា ឬមានការឯកភាពគ្នាជាមួយមេបញ្ជាការនាវា ឬនាយសន្តិសុខនាវា នៅលើប្រតិវេទន៍សន្តិសុខ ។

**មាត្រា ៣៧.-**

ការវាយតម្លៃសន្តិសុខបរិវេណកំពង់ផែ រួមមានទាំងការអង្កេតសន្តិសុខនៅនឹងកន្លែង និងកត្តាសំខាន់ៗដែលនឹងត្រូវបញ្ចូលទៅក្នុងរបាយការណ៍ ដូចខាងក្រោម:

១-កំណត់អត្តសញ្ញាណ ក្នុងការប៉ាន់តម្លៃនៃទ្រព្យ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដែលចាំបាច់ត្រូវការពារ ។

២-កំណត់អត្តសញ្ញាណនៃការគំរាមកំហែង ដែលអាចនឹងកើតមានចំពោះទ្រព្យ និងហេដ្ឋារចនាសម្ព័ន្ធ ។

៣-កំណត់អត្តសញ្ញាណ ក្នុងការជ្រើសរើស និងការកំណត់អាទិភាពនៃវិធានការទប់ទល់ ការផ្លាស់ប្តូរនីតិវិធី និងកំរិតប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពងាយរងគ្រោះ ។

៤-កំណត់អត្តសញ្ញាណនៃចំណុចខ្សោយ រួមទាំងកត្តាមនុស្សក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ គោលនយោបាយ និងនីតិវិធី ។

**មាត្រា ៣៨.-**

ផែនការសន្តិសុខបរិវេណកំពង់ផែ ត្រូវបានកសាងឡើងដោយផ្អែកលើការវាយតម្លៃសន្តិសុខបរិវេណកំពង់ផែ និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់អន្តរជាតិ និងច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៩.-**

ផែនការសន្តិសុខបរិវេណកំពង់ផែ និងការកែប្រែនៃផែនការនេះ ត្រូវមានសវនកម្មផ្ទៃក្នុងដើម្បីត្រួតពិនិត្យសកម្មភាពសន្តិសុខ ។

**មាត្រា ៤០.-**

សវនករផ្ទៃក្នុង ត្រូវមានលក្ខណៈឯករាជ្យពីសកម្មភាពសន្តិសុខ ដែលខ្លួនកំពុងធ្វើសវនកម្ម លើកលែងតែសវនករនោះ ពុំមានសមត្ថភាពគ្រប់គ្រាន់ធ្វើសវនកម្មបានដោយអាស្រ័យនឹងទំហំរបស់កំពង់ផែ ។

**មាត្រា ៤១.-**

កំពង់ផែពាក់ព័ន្ធ ត្រូវពិនិត្យឡើងវិញផែនការវាយតម្លៃបរិយាកាសផែ តាមការស្នើសុំរបស់នាយសន្តិសុខបរិយាកាសផែ ក្នុងករណីដូចខាងក្រោម:

១-ការប្រែប្រួលលើការវាយតម្លៃសន្តិសុខបរិយាកាសផែ ។

២-ចំណុចខ្វះខាតលើធាតុសំខាន់ៗនៃផែនការសន្តិសុខបរិយាកាសផែ ដែលសវនករផ្ទៃក្នុង ឬអង្គការសន្តិសុខទទួលស្គាល់បានរកឃើញ ។

៣-ឧប្បត្តិហេតុសន្តិសុខ ឬការគំរាមកំហែងសន្តិសុខ ។

៤-ការផ្លាស់ប្តូរចនាសម្ព័ន្ធគ្រប់គ្រង ឬការត្រួតពិនិត្យប្រតិបត្តិការរបស់កំពង់ផែ ។

**មាត្រា ៤២.-**

កំពង់ផែពាក់ព័ន្ធ ត្រូវធ្វើការកែប្រែផែនការសន្តិសុខបរិយាកាសផែ តាមការស្នើសុំរបស់នាយសន្តិសុខបរិយាកាសផែ ក្នុងករណីមានការផ្លាស់ប្តូរ ដែលធ្វើឱ្យប្រែប្រួលជាមូលដ្ឋានលើរបៀបរក្សាសន្តិសុខបរិយាកាសផែ ។

## ជំពូកទី ៥
## ការត្រួតពិនិត្យបច្ចេកទេស ការផ្តល់វិញ្ញាបនបត្រ និងឯកសារសន្តិសុខ

**មាត្រា ៤៣.-**

នាវាសញ្ជាតិខ្មែរ ដែលត្រូវគោរពតាមអនុក្រឹត្យនេះ ត្រូវមានការត្រួតពិនិត្យបច្ចេកទេស តាមដំណាក់កាលដូចខាងក្រោម:

១-ការត្រួតពិនិត្យបច្ចេកទេសនៅគ្រាដំបូង ឬនៅមុនពេលដាក់នាវាឱ្យប្រើប្រាស់ ឬមុនពេលផ្តល់វិញ្ញាបនបត្រសន្តិសុខនាវាជាលើកទី១ ។

២-ការត្រួតពិនិត្យបច្ចេកទេសសារជាថ្មី ។

៣-ការត្រួតពិនិត្យបច្ចេកទេសនៅក្នុងគ្រាសុពលភាពនៃវិញ្ញាបនបត្រសន្តិសុខនាវា ។

៤-ការត្រួតពិនិត្យបច្ចេកទេសបន្ថែម ។

**មាត្រា ៤៤.-**

ការត្រួតពិនិត្យបច្ចេកទេស ត្រូវធ្វើឡើងដោយ គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ។

ក្នុងគ្រប់ករណីទាំងអស់ គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ត្រូវធានាឱ្យមានការត្រួតពិនិត្យបច្ចេកទេសពេញលេញ និងត្រឹមត្រូវ ។

**មាត្រា ៤៥.-**

ក្រោយការត្រួតពិនិត្យបច្ចេកទេសហើយ ប្រព័ន្ធសន្តិសុខ និងឧបករណ៍ដែលភ្ជាប់នឹងប្រព័ន្ធនេះ ត្រូវបានកំណត់នៅក្នុងផែនការសន្តិសុខនាវា ត្រូវរក្សាប្រើប្រាស់ និងមិនត្រូវផ្លាស់ប្តូរ រើចេញ ឬបំពាក់បន្ថែម ដោយគ្មានការអនុញ្ញាតឡើយ ។

**មាត្រា ៤៦.-**

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា អាចចេញវិញ្ញាបនប័ត្រសន្តិសុខនាវាឱ្យនាវាសញ្ជាតិខ្មែរ បើនាវានោះ បានបំពេញត្រឹមត្រូវតាមលក្ខខ័ណ្ឌនៃការត្រួតពិនិត្យបច្ចេកទេសនៅគ្រាដំបូង ឬការត្រួតពិនិត្យបច្ចេកទេសសារជាថ្មីរួចមក ។

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា អាចផ្តល់បដិលេខ លើវិញ្ញាបនប័ត្រសន្តិសុខនាវាសំរាប់បញ្ជាក់អំពីការ គោរពច្បាប់ជាតិ និងច្បាប់អន្តរជាតិ ក្នុងករណីដូចខាងក្រោមៈ

១-ការត្រួតពិនិត្យបច្ចេកទេសសារជាថ្មី ។

២-ការត្រួតពិនិត្យបច្ចេកទេសនៅក្នុងគ្រាសុពលភាពនៃវិញ្ញាបនប័ត្រសន្តិសុខនាវា ។

៣-ការត្រួតពិនិត្យបច្ចេកទេសបន្ថែម ។

៤-ការពន្យារសុពលភាពនៃវិញ្ញាបនប័ត្រសន្តិសុខនាវា ។

**មាត្រា ៤៧.-**

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា អាចស្នើសុំឱ្យរដ្ឋាភិបាលជាប់កិច្ចសន្យាណាមួយដើម្បីត្រួតពិនិត្យបច្ចេកទេសនាវាសញ្ជាតិខ្មែរ ឬនាវាដែលនឹងចូលសញ្ជាតិខ្មែរ ព្រមទាំងចេញវិញ្ញាបនប័ត្រសន្តិសុខនាវា ឬផ្តល់បដិលេខលើវិញ្ញាបនប័ត្រសន្តិសុខនាវានោះ ស្របតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។

**មាត្រា ៤៨.-**

វិញ្ញាបនប័ត្រសន្តិសុខនាវា ត្រូវមានសុពលភាពប្រាំ (៥) ឆ្នាំ ។

**មាត្រា ៤៩.-**

ការត្រួតពិនិត្យបច្ចេកទេសសារជាថ្មី ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំ (៥) ឆ្នាំម្តង ដើម្បីធានាថា ប្រព័ន្ធសន្តិសុខរបស់នាវា និងឧបករណ៍ដែលភ្ជាប់នឹងប្រព័ន្ធនេះ នៅតែបំពេញបានតាមលក្ខខ័ណ្ឌទាំងឡាយនៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។

បើការត្រួតពិនិត្យបច្ចេកទេសសារជាថ្មី ត្រូវបានធ្វើចប់សព្វគ្រប់ក្នុងរយៈពេលបី (៣) ខែ មុនកាលបរិច្ឆេទផុតកំណត់នៃវិញ្ញាបនប័ត្រសន្តិសុខនាវា វិញ្ញាបនប័ត្រសន្តិសុខនាវាថ្មី ដែលត្រូវចេញ ត្រូវមានសុពលភាពចាប់តាំងពីកាលបរិច្ឆេទចប់ការត្រួតពិនិត្យរហូតដល់រយៈពេលប្រាំ (៥) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទផុតកំណត់នៃវិញ្ញាបនប័ត្រសន្តិសុខនាវាចាស់ ។

បើការត្រួតពិនិត្យបច្ចេកទេសសារជាថ្មី ត្រូវបានធ្វើចប់សព្វគ្រប់ នៅក្រោយកាលបរិច្ឆេទផុតកំណត់នៃវិញ្ញាបនប័ត្រសន្តិសុខនាវា វិញ្ញាបនប័ត្រសន្តិសុខនាវាថ្មី ដែលត្រូវចេញ ត្រូវមានសុពលភាពចាប់តាំងពីកាលបរិច្ឆេទចប់ការត្រួតពិនិត្យរហូតដល់រយៈពេលប្រាំ (៥) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទផុតកំណត់នៃវិញ្ញាបនប័ត្រសន្តិសុខនាវាចាស់ ។

បើការត្រួតពិនិត្យបច្ចេកទេសសារជាថ្មី ត្រូវបានធ្វើចប់សព្វគ្រប់ក្នុងរយៈពេលលើសពីបី (៣) ខែ មុនកាលបរិច្ឆេទផុតកំណត់នៃវិញ្ញាបនប័ត្រសន្តិសុខនាវា វិញ្ញាបនប័ត្រសន្តិសុខនាវាថ្មី ដែលត្រូវចេញ ត្រូវមានសុពលភាពចាប់តាំងពីកាលបរិច្ឆេទចប់ការត្រួតពិនិត្យរហូតដល់រយៈពេលប្រាំ (៥) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទចប់ការត្រួតពិនិត្យបច្ចេកទេសសារជាថ្មីនោះ ។

**មាត្រា ៥០.-**

ក្នុងករណី ដែលការត្រួតពិនិត្យបច្ចេកទេសសារជាថ្មី ត្រូវបានធ្វើចប់សព្វគ្រប់ តែវិញ្ញាបនប័ត្រសន្តិសុខនាវាថ្មីពុំអាចផ្តល់ជូនបាន ឬពុំអាចបញ្ជូនទៅឱ្យនាវាបាន មុនកាលបរិច្ឆេទផុតកំណត់សុពលភាពនៃវិញ្ញាបនប័ត្រសន្តិសុខនាវាចាស់ នោះគណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា អាចផ្តល់បង្អិលេខលើវិញ្ញាបនប័ត្រសន្តិសុខនាវាចាស់ ដើម្បីប្រើប្រាស់ក្នុងរយៈពេលប្រាំ (៥) ខែបន្តទៀត គិតចាប់ពីកាលបរិច្ឆេទផុតកំណត់សុពលភាព ។

**មាត្រា ៥១.-**

បើដល់ពេលផុតសុពលភាពនៃវិញ្ញាបនប័ត្រសន្តិសុខនាវា ហើយនាវាសញ្ជាតិខ្មែរ ស្ថិតនៅតាមកំពង់ផែបរទេសក្រៅពីកំពង់ផែ ដែលត្រូវបានអនុញ្ញាតឱ្យធ្វើការត្រួតពិនិត្យបច្ចេកទេសសារជាថ្មី នោះគណៈកម្មាធិការគ្រប់គ្រងការចុះ បញ្ជីនាវាសញ្ជាតិកម្ពុជា អាចពន្យារសុពលភាពនៃវិញ្ញាបនប័ត្រសន្តិសុខនាវានោះ ដែលមានរយៈពេលមិនលើសពីបី (៣) ខែ ដើម្បីឱ្យនាវានោះធ្វើដំណើរទៅដល់កំពង់ផែ ដែលត្រូវធ្វើការត្រួតពិនិត្យ ។

ក្នុងករណីនេះ បើនាវាបានធ្វើដំណើរមកដល់កំពង់ផែ ដែលត្រូវធ្វើការត្រួតពិនិត្យបច្ចេកទេសហើយ នាវានោះមិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីកំពង់ផែបានឡើយ លុះត្រាតែមានវិញ្ញាបនប័ត្រសន្តិសុខនាវាថ្មី ។

**មាត្រា ៥២.-**

ការត្រួតពិនិត្យបច្ចេកទេសនៅក្នុងគ្រាសុពលភាពនៃវិញ្ញាបនប័ត្រសន្តិសុខនាវា ត្រូវធ្វើឡើងតែម្តងគត់ ។

ការត្រួតពិនិត្យនេះ ត្រូវធ្វើឡើងនៅឆ្នាំទីបី (៣) ដើម្បីធានាថា ប្រព័ន្ធសន្តិសុខរបស់នាវា និងឧបករណ៍ភ្ជាប់នឹងប្រព័ន្ធនេះ អាចប្រើប្រាស់បានតាមការចាំបាច់ ។

**មាត្រា ៥៣.-**

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា អាចផ្ទេររាល់ព័ត៌មានដែលទាក់ទងនឹងការផ្តល់វិញ្ញាបនប័ត្រសន្តិសុខនាវា ឱ្យទៅរដ្ឋាភិបាលជាប់កិច្ចសន្យាណាមួយ ដែលនាវាសញ្ជាតិខ្មែរ នឹងត្រូវផ្ទេរទៅ បើមានការស្នើសុំ ។

ក្រុមហ៊ុននាវាចាស់ ដែលនាវារបស់ខ្លួន ត្រូវផ្ទេរទៅក្រុមហ៊ុននាវាថ្មី ត្រូវផ្ទេររាល់ព័ត៌មានដែលទាក់ទងនឹងវិញ្ញាបនប័ត្រសន្តិសុខនាវា ទៅក្រុមហ៊ុននាវាថ្មី ដើម្បីងាយស្រួលដល់ការត្រួតពិនិត្យ ។

**មាត្រា ៥៤.-**

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា អាចចេញវិញ្ញាបនប័ត្រសន្តិសុខនាវាបណ្តោះអាសន្ន ដែលមានសុពលភាពអតិបរមាប្រាំមួយ (៦) ខែ ឱ្យនាវាសញ្ជាតិខ្មែរ ក្នុងករណីដែលនាវានោះ :

១-ពុំទាន់មានវិញ្ញាបនប័ត្រសន្តិសុខនាវា ។

២-បានផ្ទេរពីសញ្ជាតិដទៃនៃរដ្ឋាភិបាល ជាប់កិច្ចសន្យាមកសញ្ជាតិខ្មែរ ។

៣-បានផ្ទេរពីសញ្ជាតិដទៃនៃរដ្ឋាភិបាល មិនជាប់កិច្ចសន្យាមកសញ្ជាតិខ្មែរ ។

៤-ពុំធ្លាប់បានប្រើប្រាស់ដោយក្រុមហ៊ុននាវា ។

ការចេញវិញ្ញាបនប័ត្រសន្តិសុខនាវាបណ្តោះអាសន្ន អាចធ្វើទៅបានបន្ទាប់ពីមានការត្រួតពិនិត្យបច្ចេកទេសដូចខាងក្រោម :

១-របាយការណ៍នៃការវាយតម្លៃសន្តិសុខនាវា ។

២-ច្បាប់ចម្លងនៃផែនការសន្តិសុខនាវា ដែលបានដាក់សុំពិនិត្យនិងយល់ព្រមហើយដែលកំពុងត្រូវអនុវត្តនៅលើនាវា ។

៣-ប្រព័ន្ធប្រកាសអាសន្ននាវា ។

៤-នាយសន្តិសុខក្រុមហ៊ុន ដែលធានាអនុវត្តច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។

៥-ប្រព័ន្ធ និងឧបករណ៍សន្តិសុខ មានដំណើរការល្អ តាមលក្ខខ័ណ្ឌដូចមានចែងនៅក្នុងផែនការសន្តិសុខនាវា ។

៦-មេបញ្ជាការនាវា នាយសន្តិសុខនាវា និងបុគ្គលិកនាវាដទៃទៀត ដែលមានភារកិច្ចសន្តិសុខជាក់លាក់ ត្រូវយល់ច្បាស់អំពីភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ស្របតាមផែនការសន្តិសុខនាវា ។

៧-នាយសន្តិសុខនាវា ត្រូវបំពេញនូវលក្ខខ័ណ្ឌទាំងឡាយ ដែលមានចែងនៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៥៥.-**

កំណត់ត្រាសន្តិសុខនាវា ត្រូវកត់ត្រាសកម្មភាពនានា ដូចមាននៅក្នុងផែនការសន្តិសុខនាវា និងត្រូវរក្សាទុកនៅលើនាវា យ៉ាងតិចសម្រាប់ការចូលផែចំនួនដប់ (១០) លើកចុងក្រោយ ។ សកម្មភាពទាំងនេះរួមមាន :

១-ការបណ្តុះបណ្តាល និងការហ្វឹកហ្វឺន ។

២-ការគំរាមកំហែងសន្តិសុខ និងឧប្បត្តិហេតុសន្តិសុខ ។

៣-ការរំលោភសន្តិសុខ ។

៤-ការផ្លាស់ប្តូរកំរិតសន្តិសុខ ។

៥-ការទាក់ទងព័ត៌មានសន្តិសុខ ដែលពាក់ព័ន្ធផ្ទាល់នឹងសន្តិសុខនាវា ឬសន្តិសុខបំរើយកណ្តូផែ ដែលនាវានោះកំពុងស្ថិតនៅ ឬបានស្ថិតនៅ ។

៦-សវនកម្មផ្ទៃក្នុង និងការត្រួតពិនិត្យឡើងវិញអំពីសកម្មភាពសន្តិសុខ ។

៧-ការពិនិត្យឡើងវិញតាមកាលកំណត់អំពីការវាយតម្លៃសន្តិសុខនាវា និងអំពីផែនការសន្តិសុខនាវា ។

៨-ការកែប្រែនៃផែនការសន្តិសុខនាវា ។

៩-ការថែរក្សា ការវាស់ស្ទង់ និងការសាកល្បងឧបករណ៍សន្តិសុខនៅលើនាវា រួមទាំងឧបករណ៍ប្រកាសអាសន្ននាវា ។

**មាត្រា ៥៦.-**

ប្រតិវេទន៍សន្តិសុខ ធ្វើឡើងក្នុងគោលបំណងដូចខាងក្រោម :

១-ធានាបង្ការនូវឧប្បត្តិហេតុ ឬការគំរាមកំហែងដែលអាចកើតមានចំពោះជីវិតមនុស្ស នាវា កំពង់ផែ និង បរិស្ថាន ។

២-ធានាឱ្យមានការព្រមព្រៀងរវាងនាវាសញ្ជាតិខ្មែរ និងកំពង់ផែបរទេស ឬរវាងនាវាសញ្ជាតិខ្មែរ និងនាវាសញ្ជាតិខ្មែរ ឬរវាងនាវាសញ្ជាតិខ្មែរ និងនាវាសញ្ជាតិដទៃទៀត ដោយបានលើកឡើងនូវវិធានការសន្តិសុខរៀងៗខ្លួន ដូចមានចែងនៅក្នុងផែនការសន្តិសុខ ។

៣-ធានាឱ្យមានការព្រមព្រៀងគ្នារវាងនាវាបរទេស និងកំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា ដែលនាវានោះប្រើប្រាស់ ។

**មាត្រា ៥៧.-**

ការព្រមព្រៀងលើប្រតិវេទន៍សន្តិសុខ ត្រូវធ្វើឡើងដោយផ្អែកលើឯកសារដូចខាងក្រោម :

១-របាយការណ៍នៃការវាយតម្លៃសន្តិសុខនាវា និងផែនការសន្តិសុខនាវា ។

២-របាយការណ៍នៃការវាយតម្លៃសន្តិសុខបរិយាកាសកំពង់ផែ និងផែនការសន្តិសុខបរិយាកាសកំពង់ផែ ។

៣-កម្រិតសន្តិសុខ ។

**មាត្រា ៥៨.-**

ប្រតិវេទន៍សន្តិសុខ ត្រូវធ្វើឡើងក្នុងករណីដូចខាងក្រោម

១-មានការស្នើសុំពីនាវាបរទេស ដែលចូលមកកំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា ។

២-មានការស្នើសុំពីនាវាសញ្ជាតិខ្មែរ ដែលចូលនៅតាមកំពង់ផែបរទេស ។

៣-មានការស្នើសុំពីនាវាសញ្ជាតិខ្មែរ ដែលមានសកម្មភាពផ្ទេរផ្ទុកទំនិញ ឬមនុស្សជាមួយនាវាបរទេស ។

៤-មានការស្នើសុំពីនាវាសញ្ជាតិខ្មែរ ដែលមានសកម្មភាពផ្ទេរផ្ទុកទំនិញ ឬមនុស្សជាមួយនាវាសញ្ជាតិខ្មែរ ។

៥-មានការស្នើសុំពីនាវាបរទេស ដែលមានសកម្មភាពផ្ទេរផ្ទុកទំនិញ ឬមនុស្សជាមួយនាវាសញ្ជាតិខ្មែរ ។

៦-មានការចាំបាច់របស់កំពង់ផែ ។

**មាត្រា ៥៩.-**

ប្រតិវេទន៍សន្តិសុខ ត្រូវធ្វើឡើង និងសម្រេចយល់ព្រមរវាង :

១-មេបញ្ជាការនាវា ឬនាយសន្តិសុខនាវា និងនាយសន្តិសុខបរិយាកាសកំពង់ផែ ។

២-មេបញ្ជាការនាវា ឬនាយសន្តិសុខនាវានៃនាវាមួយ និងមេបញ្ជាការនាវា ឬនាយសន្តិសុខនាវានៃនាវាមួយទៀត ។

**មាត្រា ៦០.-**

ប្រតិវេទន៍សន្តិសុខ ត្រូវមានសុពលភាពស្របតាមការព្រមព្រៀងគ្នា ។

ប្រតិវេទន៍សន្តិសុខ អាចអស់សុពលភាពក្នុងករណីមានការផ្លាស់ប្តូរកម្រិតសន្តិសុខ ។

**មាត្រា ៦១.-**

ក្រោយបានបំពេញលក្ខខ័ណ្ឌទាំងឡាយដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់ជាតិ និងច្បាប់អន្តរជាតិរួចមកក្រសួងសាធារណការ និងដឹកជញ្ជូន អាចចេញលិខិតបញ្ជាក់ឱ្យឋបនីយភណ្ឌផែ ដោយមានបញ្ជាក់អំពីឈ្មោះឋបនីយភណ្ឌផែ អាស័យដ្ឋានឋបនីយភណ្ឌផែ និងប្រភេទនាវា ដែលអាចប្រើប្រាស់ឋបនីយភណ្ឌផែ ។

លិខិតបញ្ជាក់ ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌ១ នៃមាត្រានេះ ត្រូវមានសុពលភាពប្រាំ (៥) ឆ្នាំ និងត្រូវមានការត្រួតពិនិត្យក្នុងគ្រាសុពលភាព ។

## ជំពូកទី ៦
## ការត្រួតពិនិត្យលើការអនុវត្តវិធានការសន្តិសុខ

**មាត្រា ៦២.-**

នៅតាមកំពង់ផែបរទេស នាវាសញ្ជាតិខ្មែរ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់សមត្ថកិច្ចត្រួតពិនិត្យនាវា ។

នៅតាមកំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា នាវា ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់សមត្ថកិច្ចត្រួតពិនិត្យនាវានៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

ការត្រួតពិនិត្យ ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌ១ និង២ នៃមាត្រានេះ អាចធ្វើឡើងដើម្បីផ្ទៀងផ្ទាត់អំពីសុពលភាពនៃវិញ្ញាបនប័ត្រសន្តិសុខនាវា ឬវិញ្ញាបនប័ត្រសន្តិសុខនាវាបណ្តោះអាសន្ន ឬឯកសារចាំបាច់របស់នាវា តែប៉ុណ្ណោះ ។

**មាត្រា ៦៣.-**

ក្នុងករណីពិនិត្យឃើញថា នាវា ពុំបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ ឬនាវា ពុំមានវិញ្ញាបនប័ត្រសន្តិសុខនាវា ដែលមានសុពលភាពទេ នោះសមត្ថកិច្ចត្រួតពិនិត្យនាវា ត្រូវចាត់វិធានការត្រួតពិនិត្យដូចខាងក្រោម :

១-ឃាត់នាវា ដើម្បីធ្វើអធិការកិច្ច និងតំរូវឱ្យនាវាធ្វើការកែចំណុចខ្វះខាត ។

២-ដាក់បំរាមលើប្រតិបត្តិការនាវា ។

**មាត្រា ៦៤.-**

មុននឹងចូលមកកំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីចៀសវាងការចាត់វិធានការត្រួតពិនិត្យនាវាបរទេស ត្រូវផ្តល់មកក្រសួងសាធារណការ និងដឹកជញ្ជូន នូវព័ត៌មានដូចខាងក្រោម :

១-វិញ្ញាបនប័ត្រសន្តិសុខនាវា រួមទាំងឈ្មោះអាជ្ញាធរដែលផ្តល់វិញ្ញាបនប័ត្រនោះ ។

២-កំរិតសន្តិសុខ ដែលនាវាកំពុងប្រើប្រាស់បច្ចុប្បន្ន ។

៣-កំរិតសន្តិសុខ ដែលនាវាបានប្រើប្រាស់នៅកំពង់ផែមុនៗ ដែលមានប្រតិបត្តិការរវាងនាវា និងផែ ស្របតាមកំណត់ត្រាសន្តិសុខ ដូចមានចែងនៅក្នុងមាត្រា ៥៥ នៃអនុក្រឹត្យនេះ ។

៤-វិធានការបន្ថែម ឬវិធានការពិសេសណាមួយ ដែលនាវាប្រើប្រាស់នៅកំពង់ផែមុនៗ ដែលមានប្រតិបត្តិការរវាងនាវា និងផែ ស្របតាមកំណត់ត្រាសន្តិសុខ ដូចមានចែងនៅក្នុងមាត្រា ៥៥ នៃអនុក្រឹត្យនេះ ។

៥-កំរិតសន្តិសុខ ដែលនាវាបានប្រើប្រាស់នៅក្នុងអំឡុងពេលមានប្រតិបត្តិការរវាងនាវា និងនាវា ។

៦-វិធានការបន្ថែម ឬវិធានការពិសេសណាមួយ ដែលនាវាបានប្រើប្រាស់នៅក្នុងអំឡុងពេលមាន ប្រតិបត្តិការរវាងនាវា និងនាវា ។

៧-ព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តសន្តិសុខសំខាន់ៗឯទៀត ។

**មាត្រា ៦៥.-**

នាវា ត្រូវរក្សាកំណត់ត្រាសន្តិសុខនាវា ដែលបានកត់ត្រាចូលនូវរាល់ព័ត៌មានសន្តិសុខ ដូចមានចែងនៅក្នុងមាត្រា ៥៥ នៃអនុក្រឹត្យនេះ ឱ្យបានយ៉ាងតិចចំនួនដប់ (១០) លើកចុងក្រោយនៃការចូលផែរបស់នាវា ។

**មាត្រា ៦៦.-**

បើពិនិត្យឃើញថា នៅមានខ្វះព័ត៌មានសន្តិសុខដូចមានចែងនៅក្នុងមាត្រា ៦៤ នៃអនុក្រឹត្យនេះ ឬមានចំណុចខ្វះខាតផ្នែកសន្តិសុខ សមត្ថកិច្ចត្រួតពិនិត្យនាវានៃក្រសួងសាធារណការ និងដឹកជញ្ជូន អាចទាក់ទងជាមួយនាវាបរទេស ឬ ប្រទេសម្ចាស់សញ្ជាតិនាវានោះ ដើម្បីបំពេញបន្ថែមឱ្យបានត្រឹមត្រូវ ។

ក្នុងករណីទំនាក់ទំនងកែតម្រូវ ពុំបានសម្រេច ឬមានការជឿជាក់ថា ពុំបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ នោះសមត្ថកិច្ចត្រួតពិនិត្យនាវា ត្រូវចាត់វិធានការដូចតទៅ :

១-តម្រូវឱ្យធ្វើការកែតម្រូវចំណុចដែលមិនគោរពតាមបទប្បញ្ញត្តិជាបន្តទៀត ។

២-តម្រូវឱ្យនាវាទៅកាន់កន្លែងណាមួយនៅក្នុងតំបន់សមុទ្រដែនដី ឬតំបន់ទឹកផ្ទៃក្នុង ។

៣-ធ្វើអធិការកិច្ចលើនាវា ។

៤-បដិសេធនឹការចូលមកកាន់កំពង់ផែនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦៧.-**

ក្នុងករណីចាត់វិធានការដូចមានចែងនៅក្នុងមាត្រា ៦៦ នៃអនុក្រឹត្យនេះ សមត្ថកិច្ចត្រួតពិនិត្យនាវា ត្រូវធ្វើសេចក្តីជូនដំណឹងអំពីវិធានការទាំងនោះទៅប្រទេសម្ចាស់សញ្ជាតិនាវា ឬក្រុមហ៊ុនសន្តិសុខ ដែលចេញវិញ្ញាបនប័ត្រសន្តិសុខ ។

**មាត្រា ៦៨.-**

ក្នុងករណីបដិសេធនីការចូល ឬការបង្ខំឱ្យនាវាចាកចេញ ក្រសួងសាធារណការ និងដឹកជញ្ជូន អាចធ្វើសេចក្តីជូនដំណឹងទៅកំពង់ផែ ដែលនាវានោះ ត្រូវធ្វើដំណើរទៅដោយមានបញ្ជាក់អំពីមូលហេតុសមស្រប ។

## ជំពូកទី ៧
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ៦៩.-**

ការគ្រប់គ្រងសន្តិសុខនាវា នៃនាវាគ្រប់ប្រភេទដែលមិនធ្វើនាវាចរណ៍ជាលក្ខណៈអន្តរជាតិ ឬនៃនាវាទំនិញគ្រប់ប្រភេទដែលមានចំណុះសរុបតិចជាងប្រាំរយ (៥00)GT ឬនៃនាវារបស់រដ្ឋដែលមិនបំរើគោលដៅពាណិជ្ជកម្ម និងការគ្រប់គ្រងសន្តិសុខកំពង់ផែ ដែលបំរើសេវាឱ្យនាវាទាំងនេះ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

**មាត្រា ៧០.-**

ក្រសួងសាធារណការ និងដឹកជញ្ជូន អាចធ្វើកិច្ចព្រមព្រៀងជាមួយនឹងរដ្ឋាភិបាលជាប់កិច្ចសន្យាណាមួយ ឬច្រើន ដើម្បីធានាឱ្យមានវិធានការសន្តិសុខនាវាសមស្រប នៅតាមផ្លូវនាវាចរណ៍ខ្លី និងជាកំណត់រវាងកំពង់ផែអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងកំពង់ផែអន្តរជាតិនៃរដ្ឋជាប់កិច្ចសន្យានោះ ហើយអនុវត្តចំពោះតែនាវា នៃព្រះរាជាណាចក្រកម្ពុជា និងនាវានៃរដ្ឋជាប់កិច្ចសន្យានោះប៉ុណ្ណោះ ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៧១.-**

ក្រសួងសាធារណការ និងដឹកជញ្ជូន មានសិទ្ធិបដិសេធន៍ ឬព្យួរ ឬដកហូតវិញ្ញាបនប័ត្រសមត្ថភាពជំនាញ ឬវិញ្ញាបនប័ត្របដ្ឋិលេខរបស់នាយសន្តិសុខថបនីយភណ្ឌផែ ដែលរំលោភនឹងមាត្រា១៥ នៃអនុក្រឹត្យនេះ ។

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា មានសិទ្ធិបដិសេធន៍ ឬព្យួរ ឬដកហូតវិញ្ញាបនប័ត្រសមត្ថភាពជំនាញ ឬវិញ្ញាបនប័ត្របដ្ឋិលេខរបស់នាយសន្តិសុខនាវា ដែលរំលោភនឹងមាត្រា១៣ និងនាយសន្តិសុខក្រុមហ៊ុន ដែលរំលោភនឹងមាត្រា ១៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧២.-**

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា ចាត់ទុកជាមោឃៈ នូវផែនការសន្តិសុខនាវា ឬការកែប្រែផែនការសន្តិសុខនាវា ក្នុងករណីដូចខាងក្រោមៈ

១-ក្រុមហ៊ុននាវា បានរំលោភនឹងមាត្រា ១២ និងមាត្រា ១៧ នៃអនុក្រឹត្យនេះ ។

២-នាយសន្តិសុខក្រុមហ៊ុន ឬនាយសន្តិសុខនាវា បានរំលោភនឹងមាត្រា ៣០ មាត្រា ៣១ និងមាត្រា ៤៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧៣.-**

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា មានសិទ្ធិបដិសេធន៍ ឬដកហូតវិញ្ញាបនប័ត្រសន្តិសុខនាវា ក្នុងករណីមោឃភាពនៃផែនការសន្តិសុខនាវា ឬមោឃភាពនៃការ កែប្រែផែនការសន្តិសុខនាវា ។

**មាត្រា ៧៤.-**

ក្រសួងសាធារណការ និងដឹកជញ្ជូន មានសិទ្ធិបដិសេធន៍មិនទទួលស្គាល់ លើផែនការសន្តិសុខបរិវេណកំពង់ផែ ឬការកែប្រែផែនការសន្តិសុខបរិវេណកំពង់ផែ ក្នុងករណីស្ថាប័នសមត្ថកិច្ចកំពង់ផែ ពុំបានគោរពតាមលក្ខខ័ណ្ឌទាំងឡាយដូចមានចែងនៅក្នុងអនុក្រឹត្យនេះ ឬបានរំលោភនឹងមាត្រា ១៧ ឬមាត្រា ៣៨ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧៥.-**

ក្រសួងសាធារណការ និងដឹកជញ្ជូន មានសិទ្ធិបដិសេធន៍ មិនទទួលស្គាល់នាយសន្តិសុខបរិវេណកំពង់ផែ បើការជ្រើសរើស និងតែងតាំងនាយសន្តិសុខនេះ រំលោភនឹងមាត្រា២០ នៃអនុក្រឹត្យនេះ ។

គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា មានសិទ្ធិបដិសេធន៍ មិនទទួលស្គាល់នាយសន្តិសុខនាវា ឬនាយសន្តិសុខក្រុមហ៊ុន បើការជ្រើសរើស និងតែងតាំងនាយសន្តិសុខទាំងនេះ រំលោភនឹងមាត្រា១៨ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧៦.-**

នាវាបរទេស ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់ជាតិ ឬពុំបានបំពេញតាមលក្ខខ័ណ្ឌដូចមានចែងនៅក្នុងមាត្រា៦៦ នៃអនុក្រឹត្យនេះ ឬនឹងគំរាមកំហែងដល់សន្តិសុខបរិវេណកំពង់ផែ ជីវិតមនុស្ស និងនាវាដទៃទៀតនៅកំពង់ផែ ហើយដែលការគំរាមកំហែងនោះ ពុំមានមធ្យោបាយណាមួយទប់ស្កាត់បាន ត្រូវចាត់ទុកថាបានរំលោភនឹងមាត្រា២៨ នៃអនុក្រឹត្យនេះ នាវានោះនឹងត្រូវៈ

១-បញ្ជាឱ្យនាវាទៅកាន់ការដ្ឋានជួសជុល ឬការដ្ឋានសាងសង់នាវា ដែលស្ថិតនៅជិតបំផុត ។

២-បញ្ជាឱ្យនាវាចាកចេញពីកំពង់ផែ ឬតំបន់សមុទ្រផ្ទៃក្នុង ឬតំបន់សមុទ្រដែនដីជាបន្ទាន់ ។

**មាត្រា ៧៧.-**

ការឃាត់នាវាដោយគ្មានមូលហេតុសមស្រប ដូចមានចែងនៅក្នុងមាត្រា៦៣ នៃអនុក្រឹត្យនេះ ត្រូវទទួលនូវសំណងការខូចខាត ។

**មាត្រា ៧៨.-**

ក្រសួងសាធារណការ និងដឹកជញ្ជូន គណៈកម្មាធិការគ្រប់គ្រងការចុះបញ្ជីនាវាសញ្ជាតិកម្ពុជា អង្គភាពជំនាញក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន ក្រុមហ៊ុនសន្តិសុខ ក្រុមហ៊ុននាវា នាយសន្តិសុខនាវា នាយសន្តិសុខក្រុមហ៊ុន នាយសន្តិសុខបរិវេណកំពង់ផែ ដែលក្នុងពេលបំពេញភារកិច្ច បានប្រើប្រាស់តួនាទីភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន ដោយបំពាននឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬបានបង្ករការលំបាកដល់ប្រតិបត្តិការនាវាចរណ៍ និងកំពង់ផែដោយគ្មានមូលហេតុត្រឹមត្រូវ ទទួលទោសតាមច្បាប់ជាធរមាន វៀរលែងតែមានកិច្ចព្រមព្រៀងអន្តរជាតិដោយឡែកប៉ុណ្ណោះ ។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**មាត្រា ៧៩.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៦

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ៨០
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ស៊ុន ចាន់ថុល